**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៥១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតឃុំបឹងប្រាំ នៃស្រុកបវេល ខេត្តបាត់ដំបង

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

www.pheakdeylaw.com

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត**ឃុំបឹងប្រាំ** នៃស្រុកបវេល ខេត្តបាត់ដំបង ដោយកាត់យកភូមិក្រពើសៃសិបពីឃុំល្វា កាត់យកដីមួយផ្នែកពីភូមិបឹងជំនៀង ឃុំព្រៃខ្ពស់ និងកាត់យកភូមិចំនួន ៧ ពីឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង គឺភូមិសំណាងព្រះស្រី ភូមិយុត្តិធម៌ ភូមិជ័យជំនះ ភូមិបឹងធុង ភូមិអូរឫស្សី ភូមិបឹងប្រាំ និងភូមិបឹងក្រឡ ។

ព្រំប្រទល់រដ្ឋបាលនៃ**ឃុំបឹងប្រាំ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ទីតាំងសាលា**ឃុំបឹងប្រាំ** ត្រូវស្ថិតនៅក្នុងភូមិសំណាងព្រះស្រី ។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ឃុំបឹងប្រាំ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៤.-**

ការបង្កើត**ឃុំបឹងប្រាំ** ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិទី ៣ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំល្វាត្រូវបន្តគ្រប់គ្រងភូមិក្រពើសៃសិប ក្រុមប្រឹក្សាឃុំព្រៃខ្ពស់ត្រូវបន្តគ្រប់គ្រងដីមួយផ្នែកខាងលើនេះ និងក្រុមប្រឹក្សាឃុំអំពិលប្រាំដើមត្រូវបន្តគ្រប់គ្រងភូមិចំនួន ៧ ខាងលើនេះ រហូតដល់មានក្រុមប្រឹក្សាឃុំបឹងប្រាំមកជំនួស ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាខេត្តបាត់ដំបង គណៈអភិបាលខេត្តបាត់ដំបង ក្រុមប្រឹក្សាស្រុកបវេល គណៈអភិបាលស្រុកបវេល ក្រុមប្រឹក្សាឃុំល្វា ក្រុមប្រឹក្សាឃុំព្រៃខ្ពស់ ក្រុមប្រឹក្សាឃុំអំពិលប្រាំដើម និងក្រុមប្រឹក្សាឃុំបឹងប្រាំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ផែនទីព្រំប្រទល់រដ្ឋបាល ឃុំបឹងប្រាំ និងឃុំឃ្លាំងមាស
ស្ថិតនៅក្នុងស្រុកបវេល ខេត្តបាត់ដំបង
ខេត្តបន្ទាយមានជ័យ
ស្រុកសំពៅលូន
ស្រុកភ្នំព្រឹក
ស្រុកថ្មគោល
ស្រុកកំរៀង
ឃុំឃ្លាំងមាស
ស្រុកបាណន់
N
W
E
S
1:100,000
0 1.5 3 6
Km
UTM
48N
WGS1984
PheakdeyLaw Book Store